# ក្រុមមេធាវីការពារក្ដី មាស មុត
# MEAS MUTH DEFENCE TEAM
# EQUIPE DE DEFENSE DE MEAS MUTH

**អាង ឧត្ដម** និង Michael G. KARNAVAS
សហមេធាវីរបស់លោក មាស មុត
ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Feb-2014, 13:07
CMS/CFO: Sann Rada

ជូនចំពោះ៖ **លោក Isaac ENDELEY**
ប្រធានអង្គភាពគាំពារការការពារក្ដី

ចម្លងជូន៖ **លោក Eric HUSKETH**
មន្ត្រីផ្នែកច្បាប់ អង្គភាពគាំពារការការពារក្ដី

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គបុរេជំនុំជម្រះ**

កម្មវត្ថុ៖ បញ្ជាក់អំពីកិច្ចពិភាក្សាទាក់ទងនឹងលិខិតចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤ របស់សហចៅក្រមស៊ើបអង្កេត Harmon

**ជូនចំពោះលោក Endeley**

តាមរយៈលិខិតនេះ យើងសូមបញ្ជាក់អំពីការសន្ទនាពីមុនរបស់យើងទាក់ទងនឹងលិខិត ដែលលោកទទួលបានពីសហចៅក្រមស៊ើបអង្កេត Harmon នៅថ្ងៃ សុក្រ ទី ៣១ ខែមករា ឆ្នាំ ២០១៤ នៅវេលាម៉ោងប្រហែលជា ៤ និង ៤៣ នាទី ល្ងាច។ លោកមិនអាចផ្តល់មកឱ្យយើងបានឡើយ នូវច្បាប់ចម្លងមួយច្បាប់នៃលិខិតនេះ ដោយគ្មាន ដីកាតុលាការ ពីព្រោះថា យើងមិនស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកដែលត្រូវទទួលបានលិខិតនេះ។ យើងសូមថ្លែងអំណរគុណចំពោះលោកដោយស្មោះ ដែលបានប្រាប់ឱ្យយើងដឹងអំពីបញ្ហានេះ។

យើងយល់ថា សហចៅក្រមស៊ើបអង្កេត Harmon ឥឡូវនេះកំពុងតែបង្គាប់លោកឱ្យអនុវត្តដីការបស់គាត់ដោយចាត់តាំងមេធាវីការពារក្តីបណ្តោះអាសន្ន វៀរលែងតែលោកត្រូវបានបង្គាប់ឱ្យធ្វើផ្ទុយពីនេះ ដោយ

អង្គបុរេជំនុំជម្រះ។ យើងក៏យល់ទៀតថា លោកមានបំណងចាប់ផ្តើមភ្លាមៗ ក្នុងការកំណត់អត្តសញ្ញាណ និងទាក់ទងមេធាវីជាតិ និងអន្តរជាតិ ដើម្បីជំនួសក្រុមមេធាវីការពារក្តីរបស់លោក មាស មុត។

នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សារបស់យើង យើងបានជូនដំណឹងដល់លោកថា យើងនឹងដាក់សំណើជាបន្ទាន់ ស្នើឲ្យអង្គបុរេជំនុំជម្រះចាត់វិធានការលើសំណើសុំផ្អាកការអនុវត្តដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលកំពុងស្ថិតក្នុងការរង់ចាំសេចក្តីសម្រេច។ ដើម្បីឲ្យមានតម្លាភាព យើងចម្លងលិខិតនេះជូនអង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេត។

សូមលោកទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

សហមេធាវីរបស់លោក មាស មុត

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**